# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣
# របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តបាត់ដំបង

## សេចក្តីផ្តើម

ខេត្តបាត់ដំបងស្ថិតនៅពាយ័ព្យនៃប្រទេសដែលមានចម្ងាយ **២៩១** គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបទំហំ**១១,៧៤៨** គម$^{២}$ ហើយចែកចេញជា **១៣** ស្រុក និងក្រុង **០១** ដែលមាន **៩២** ឃុំ និង **១០** សង្កាត់ មាន **៨២៩** ភូមិ ប្រជាពលរដ្ឋសរុបក្នុងខេត្ត មានចំនួន **២៧៦,៤៥២** គ្រួសារ មនុស្សរាយសរុប**១,៣១២,០៥១** នាក់ ក្នុងនោះមានស្ត្រីចំនួន **៦៦០,៩៧៥** នាក់។ ដង់ស៊ីតេប្រជាពលរដ្ឋក្នុងខេត្តមាន **១០៦** នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា និងចំណូលប្រចាំឆ្នាំក្នុងម្នាក់ **១,៦១៦** ដុល្លារ។

## I. សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ១.១. ការងាររដ្ឋបាល និងបុគ្គលិក

- បានធ្វើលិខិតចេញចំនួន ៤៨៦ ច្បាប់
- បានទទួលលិខិតចូលចំនួន ៤៦៩ ច្បាប់
- បានរៀបចំបញ្ជីវត្តមានមន្ត្រីរាជការប្រចាំខែ រៀងរាល់ខែ
- បានរៀបចំកម្មវិធីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិ ០៨ មីនា ខួបលើកទី ១១១ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង
- យោងប្រកាសលេខ ០៧១/២២ ក.អ.ជ-ប្រកចុះថ្ងៃទី ៣១ ខែមីនាឆ្នាំ ២០២២ ស្តីពីការដាក់មន្ត្រីរាជការអោយចូលនិវត្តន៍
- យោងប្រកាសលេខ០៨៥/២២ក.អ.ជ-ប្រក ចុះថ្ងៃទី ២៧ ខែមេសា ២០២២ សម្រេចផ្ទេរភារកិច្ចលោកស្រី **ថុល ដានី** មន្ត្រីបម្រើការងារនៅការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង ឲ្យទៅបម្រើការងារ ជាមន្ត្រីនៃនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុនៃក្រសួងអភិវឌ្ឍន៍ជនបទ
- ក្នុងឆ្នាំ ២០២២ នេះ មន្ត្រីបានឡើងឋានន្តរស័ក្តិ និងថ្នាក់ចំនួន ៣៥ រូប ស្ត្រី ១០ រូប
- យោងដីកាលេខ ០៦២/២២ដក.តត ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការផ្លាស់ប្តូរភារកិច្ច តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការៈ

  ១. លោក **ពៅ ដាលីនណា** បច្ចុប្បន្នប្រធានការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ អោយកាន់មុខដំណែងជាប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍ ។

  ២. លោក **អ៊ួម ណារ៉ែម** បច្ចុប្បន្នអនុប្រធានការិយាល័យផ្គត់ផ្គង់ទឹកជនបទ អោយកាន់

មុខដំណែងជាអនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍ ។

៣. លោកស្រី **សំ សុភ័ក្រ** អោយកាន់មុខដំណែងជាអនុប្រធានការិយាល័យផ្គត់ផ្គង់ទឹកជនបទ ។

៤. លោកស្រី **ផៃ សុភីរ៉ា** អោយកាន់មុខដំណែងជាអនុប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ។

៥. លោក **សោម ប៊ុនជោង** អោយកាន់មុខដំណែងជា ប្រធានការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ

**១.២. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ**

- ប្រធាន អនុប្រធានមន្ទីរ និងមន្ត្រីរាជការមួយចំនួនបានចូលរួមប្រជុំផ្សេងៗចំនួន ២៩៩ លើក ក្នុងនោះចូលរួមប្រជុំ Online ១៧ លើក ប្រជុំក្នុងខេត្តចំនួន ២៥២ លើក និងក្រៅខេត្តចំនួន ៣០ លើក
- មន្ត្រីមន្ទីរបានចូលរួមវគ្គសិក្ខាសាលា ក្នុងប្រទេស និងក្រៅប្រទេសសរុបចំនួន ៥៦ នាក់ ស្ត្រី ២៣ នាក់ ដូចជា៖
  - បានចូលរួមសិក្ខាសាលាចំនួន ៣០ នាក់ ស្ត្រី ១៣ នាក់
  - បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន ២៦ នាក់ ស្ត្រី ១០ នាក់
- បានចុះផ្សព្វផ្សាយជ្រើសរើសសិស្សចូលរៀន ជំនាញជួសជុលម៉ាស៊ីនកសិកម្មខ្នាតតូច បច្ចេកទេសប្រើប្រាស់កុំព្យូទ័ររដ្ឋបាលវគ្គទី ១ ឆ្នាំ ២០២២ នៅក្នុងឃុំគោលដៅចំនួន ០១ គឺឃុំដូនបា ស្រុកគាស់ក្រឡ មានអ្នកចូលរួមសរុបចំនួន ៧២ នាក់ ស្ត្រី ៤៦ នាក់
- បានបើកវគ្គបណ្តុះបណ្តាលរយៈពេល ០៤ ខែ វគ្គទី ១ ឆ្នាំ ២០២២ ដែលមានសិស្សសរុបចំនួន ៣៧ នាក់ ស្ត្រី ២១ នាក់ តាមជំនាញដូចខាងក្រោម៖
  - ជំនាញជួសជុលម៉ាស៊ីនកសិកម្មខ្នាតតូច សិស្សសរុបចំនួន ០៦ នាក់ គ្មានស្ត្រី
  - បច្ចេកទេសប្រើប្រាស់កុំព្យូទ័ររដ្ឋបាល សិស្សសរុបចំនួន ៣១ នាក់ ស្ត្រី ២១ នាក់
- បានបញ្ចប់វគ្គបណ្តុះបណ្តាលរយៈពេល ០៤ ខែ វគ្គទី ១ ឆ្នាំ ២០២២ ដែលមានសិស្សសរុបចំនួន ៤០ នាក់ ស្ត្រី ២៣ នាក់ តាមជំនាញដូចខាងក្រោម៖
  - ជំនាញជួសជុលម៉ាស៊ីនកសិកម្មខ្នាតតូច សិស្សសរុបចំនួន ០៦ នាក់ គ្មានស្ត្រី
  - ជំនាញបច្ចេកទេសប្រើប្រាស់កុំព្យូទ័ររដ្ឋបាល សិស្សសរុបចំនួន ៣៤ នាក់ ស្ត្រី ២៣ នាក់
- បានចុះផ្សព្វផ្សាយជ្រើសរើសសិស្សចូលរៀន ជំនាញជួសជុលគ្រឿងយន្តកសិកម្មខ្នាតតូចវគ្គទី ២ ជំនាញថែទាំគ្រឿងយន្តកសិកម្ម ចិញ្ចឹមមាន់ បណ្តុះផ្សិតចំបើងនិងសួនបន្លែគ្រួសារ នៅឃុំតាប៉ុន ស្រុកសង្កែ
- បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី(១០ថ្ងៃ)ចំនួន ៣ វគ្គ នៅឃុំតាប៉ុន ស្រុកសង្កែ ដែលមានសិស្សសរុបចំនួន ១២០ នាក់ ស្ត្រី ៣៦ នាក់ តាមជំនាញដូចខាងក្រោម៖
  - ជំនាញចិញ្ចឹមមាន់ សិស្សសរុបចំនួន ២០ នាក់ ស្ត្រី ១៣ នាក់

- ជំនាញបណ្តុះផ្សិតចំបើង សិស្សសរុបចំនួន ២០ នាក់ ស្ត្រី ១៤ នាក់
- ជំនាញសួនបន្លែគ្រួសារ សិស្សសរុបចំនួន ២០ នាក់ ស្ត្រី ០៩ នាក់
- ជំនាញថែទាំគ្រឿងយន្តកសិកម្ម សិស្សសរុបចំនួន ៦០ នាក់ គ្មានស្ត្រី

- បានបើកវគ្គបណ្តុះបណ្តាលរយៈពេល ៤ ខែ ជំនាញជួសជុលគ្រឿងយន្តកសិកម្មខ្នាតតូចវគ្គទី ២ ដែលមានសិស្សសរុបចំនួន ១៧ នាក់ គ្មានស្ត្រី
- បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី (១០ថ្ងៃ) ជំនាញថែទាំគ្រឿងយន្តកសិកម្ម ចំនួន ០៣ វគ្គនៅឃុំវត្តតាមិម ស្រុកសង្កែ ដែលមានសិស្សសរុបចំនួន ៦០ នាក់ គ្មានស្ត្រី

### ១.៣. ការងារផែនការ និងស្ថិតិ

- បានធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ប្រចាំត្រីមាសទី១ ប្រចាំឆមាសទី ១ ប្រចាំត្រីមាសទី ៣ និងប្រចាំឆ្នាំ ២០២២
- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០២៣-២០២៥
- បានរៀបចំផែនការថវិកាឆ្នាំ ២០២៣
- បានរៀបចំផែនការវិនិយោគបីឆ្នាំរំកិល ឆ្នាំ ២០២៣-២០២៥
- បានចុះត្រួតពិនិត្យស្ថានភាពផ្លូវមុនការសាងសង់ចំនួន ២ ខ្សែ ខ្សែទី ១ ប្រវែង ១១ គម នៅស្រុករតនមណ្ឌល និងខ្សែទី ២ ប្រវែង ១២.០០ គម នៅស្រុកសំឡូត
- បានចុះតាមដាន និងត្រួតពិនិត្យការសាងសង់ផ្លូវថែទាំលក្ខណៈប្រចាំចំនួន ០២ លើក លើផ្លូវ ០៣ ខ្សែ នៅឃុំជ្រៃសីម៉ា ស្រុកសំពៅលូននិងឃុំដូនបា ស្រុកគាស់ក្រឡ។

### ១.៤. ការងារគណនេយ្យ និងហិរញ្ញវត្ថុ

បានរៀបចំឯកសារចំណាយ និងប្រើប្រាស់ថវិកាចរន្តតាមជំពូកថវិកា៖

- ក្នុងជំពូក ៦០ (ការទិញ)ក្នុងផែនការ ១២៨,៣០០,០០០ រៀល សម្រេចបាន ៨៤%
- ក្នុងជំពូក ៦១(សេវាខាងក្រៅ)ក្នុងផែនការ ១,៧៦៧,៣០០,០០០ រៀលសម្រេចបាន ៩៩%
- ក្នុងជំពូក ៦៣(ពន្ធនិងអាករ)ក្នុងផែនការ ៣,៦០០,០០០ រៀល សម្រេចបាន ៣៩%
- ក្នុងជំពូក ៦៤(បន្ទុកបុគ្គលិក)ក្នុងផែនការ ៩២៥,១០០,០០០ រៀល សម្រេចបាន ៩១%។

## ២. ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

### ២.១. ការងារធ្វើបច្ចុប្បន្នភាពផ្លូវជនបទ រាប់យានយន្ត និងដាំកូនឈើ

- បានចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌផ្លូវជនបទនៅ ស្រុកកំរៀង ស្រុកមោងឫស្សី និងស្រុកសំឡូត បានចំនួន ២០ ខ្សែ ប្រវែង ២៥២.២០ គម ដូចជា៖
  - ផ្លូវជនបទប្រភេទ ១ មានចំនួន ០៣ ខ្សែ ប្រវែង ៣៤.៤០ គម
  - ផ្លូវជនបទប្រភេទ ២ មានចំនួន ០២ ខ្សែ ប្រវែង ២០.៨០ គម
  - ផ្លូវជនបទប្រភេទ ៣ មានចំនួន ១៥ ខ្សែ ប្រវែង ១៩៧.០០ គម

- បានចុះរាប់យានយន្តដែលចរាចរណ៍លើខ្សែផ្លូវថែទាំជាលក្ខណៈខួប ០១ ខ្សែ ស្ថិតក្នុង ឃុំតាសាញ ស្រុកសំឡូត ចំនួន ០៣ លើក ស្ថិតក្នុង ឃុំតាសាញ ស្រុកសំឡូត សរុបមានដូចជា ៖អ្នកថ្មើជើង ១០៣ នាក់, កង់ ៣៣៥ គ្រឿង,ម៉ូតូ ៣ ៩៣៣ គ្រឿង, រ៉ឺម៉កកង់បី/រ៉ឺម៉កម៉ូតូ ១៤៣ គ្រឿង, រទេះសត្វ ៩ រទេះ, គោយន្ត/ត្រាក់ទ័រដៃ ៦៦០ គ្រឿង, ត្រាក់ទ័រកសិកម្មធុនធំ ២៨៥ គ្រឿង, ឡានតូច/តាក់ស៊ី ២៣៤ គ្រឿង, ឡានមួយចាំងកន្លះ៣៣៧គ្រឿង,ឡានដឹកទំនិញខ្នាតតូច(១-២តោន)១ ៦៦៧ គ្រឿង,ឡានដឹកទំនិញធុនស្រាល (តិចជាង ៥ តោន) ១ ០៧៧ គ្រឿង,ឡានដឹកទំនិញធុនមធ្យម(៥-១០តោន) ៧១៥ គ្រឿង។
- បានចុះដាំកូនឈើចំនួន ០២ លើក តាមបណ្តោយខ្សែផ្លូវថែទាំខួប ០១ ខ្សែ ពីភូមិអូរស្ងួត ឃុំតាសាញទៅ ភូមិរំចេកក្រោម ស្ថិតក្នុង ឃុំតាសាញ ស្រុកសំឡូត ប្រវែង ១២.០០ គម សរុបបាន កូនឈើ អាកាសស្យា ចំនួន ១ ៨០០ ដើម និងកូនឈើក្រោក ៤០០ ដើម។

**២.២. គាំទ្រថវិកា ដោយក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០២២**

**ផ្លូវថែទាំជាប្រចាំ ក្រាលគ្រួសក្រហម និងកំទេចថ្មភ្នំ សរុបមានចំនួន០៨ខ្សែ ប្រវែង ១២៤.៦០ គម**

- ខ្សែទី ១ ប្រវែង ១១.០០ គម អនុវត្តបាន ១០០% (ពីផ្លូវជាតិលេខ ៥៧ ទៅភូមិអណ្តើកហែបស្ថិតក្នុងឃុំអណ្តើកហែប ស្រុករតនមណ្ឌល)
- ខ្សែទី ២ ប្រវែង ១២.០០ គម អនុវត្តបាន ១០០% (ពីផ្លូវលេខ ៥៧ ទៅភូមិបឹងក្រសាល ស្ថិតក្នុងឃុំស្នឹង ស្រុកបាណន់)
- ខ្សែទី ៣ ប្រវែង ២២.២០ គម អនុវត្តបាន ១០០% (ពីភូមិបឹងបីទៅឃុំព្រះផុស ស្ថិតក្នុងឃុំមោង ស្រុកមោងឫស្សី និងឃុំព្រះផុស ស្រុកគាស់ក្រឡ)
- ខ្សែទី ៤ ប្រវែង ១៧.០០ គម អនុវត្តបាន ១០០% (ពីផ្លូវជាតិ ៥៩ ទៅភូមិឡាក់ហុកពីរ ស្ថិតក្នុងឃុំកំរៀង ស្រុកកំរៀង)
- ខ្សែទី ៥ ប្រវែង ៩.០០ គម អនុវត្តបាន ១០០% (ពីផ្លូវឃុំគាស់ក្រឡទៅដូនបា ស្ថិតក្នុង ឃុំដូនបា ស្រុកគាស់ក្រឡ)
- ខ្សែទី ៦ ប្រវែង ១៦.៤០ គម អនុវត្តបាន ១០០% (ពីភូមិបឹងព្រីង ឃុំបឹងព្រីង ស្រុកថ្មគោលទៅឃុំល្វា ស្រុកបវេល)
- ខ្សែទី ៧ ប្រវែង ១១.០០ គម អនុវត្តបាន ១០០% (ពីផ្លូវភូមិអូរល្ងាទៅភ្នំឫស្សី ស្ថិតក្នុងឃុំជ្រៃសីម៉ា ស្រុកសំពៅលូន)
- ខ្សែទី ៨ ប្រវែង ២៦.០០ គម អនុវត្តបាន ១០០% (ពីផ្លូវជាតិលេខ ៥៩ ទៅភូមិអូរកាច់ ស្ថិតក្នុងឃុំជ្រៃសីម៉ាស្រុកសំពៅលូន)

**ផ្លូវថែទាំជាលក្ខណៈខួបក្រាលល្បាយកំទេចថ្មភ្នំ សរុបមានចំនួន០១ខ្សែ ស្មើនឹង ១២ គម៖** ផ្លូវនេះមានប្រវែង ១២.០០ គម និងលូកាត់ផ្លូវចំនួន ២ កន្លែងអនុវត្តបាន

១០០% (ពីភូមិអូរស្នួត ឃុំតាសាញទៅភូមិរំចេកក្រោមស្ថិតក្នុង ឃុំតាសាញ ស្រុកសំឡូត)។

**ផ្លូវជួសជុលបន្ទាន់ ឆ្នាំ ២០២២ សរុបមានចំនួន ០១ ខ្សែ ស្មើនឹង ២.៦០ គីឡូម៉ែត្រ៖** ផ្លូវក្រាលក្រួសធម្មជាតិប្រវែង២.៦០គមអនុវត្តបាន១០០%(ផ្លូវក្នុងភូមិម៉ាណោកស្ថិតក្នុងឃុំតាលាស់ ស្រុកមោងឫស្សី) ។

**២.៣. គាំទ្រថវិកា ដោយវិនិយោគខេត្ត ឆ្នាំ២០២២**

**ផ្លូវស្តារឡើងវិញក្រាលកៅស៊ូ សរុបមានចំនួន ០២ ខ្សែ ប្រវែង ០.៩៨៤ គម**

- ខ្សែទី ១ ប្រវែង ០.៣៧៤ គម អនុវត្តបាន ១០០%(ផ្លូវលេខ ៣១៣ ស្ថិតក្នុងសង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង)។
- ខ្សែទី ២ ប្រវែង ០.៦១០ គម អនុវត្តបាន ១០០% (ផ្លូវលេខ ៧១៧ ស្ថិតក្នុងសង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង)។

**២.៤. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទនិងការគាំទ្រកសិករ**

- ការងារសាងសង់ផ្លូវក្រាលល្បាយថ្មធម្មជាតិ ចំនួន ២ ខ្សែ ប្រវែងសរុប ២១,២០០ ម ក្នុងឃុំព្រៃតូច ស្រុកមោងឫស្សី និងឃុំដូនបា ស្រុកគាស់ក្រឡ សម្រេចបាន ១០០%។
- បានសាងសង់ផ្លូវដើស ចំនួន ០៨ ខ្សែ ប្រវែង ៤១,៦០០ ម នៅឃុំឫស្សីក្រាំង ឃុំរបស់មង្គល ស្រុកមោងឫស្សី និង ឃុំដូនបា ស្រុកគាស់ក្រឡ សម្រេចបាន ១០០%។

**៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**៣.១. ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ**

**៣.១.១. គាំទ្រថវិកាដោយក្រសួងអភិវឌ្ឍន៍ជនបទ**

- បានចូលរួមប្រជុំជាមួយអង្គការទឹកស្អាត ១០០១ សម្រាប់ការសាងសង់ស្ថានីយ៍ផលិតទឹកពិសាអូរី មាននៅទីតាំងស្រុកឯកភ្នំ ស្រុកបាណន់ ស្រុកថ្មគោល ស្រុកបវេល ស្រុកសំពៅលូន និងស្រុកកំរៀង។
- បានចូលរួមប្រជុំជាមួយអង្គការទឹកស្អាត ១០០១ ក្នុងការរៀបចំនិងដំណើរការឡើងវិញនូវ ស្ថានីយផលិតទឹកដែលបានផ្អាកសកម្មភាពមួយចំនួននៅឃុំតាពូង ស្រុកថ្មគោលនិងឃុំស្តៅ ស្រុករតនមណ្ឌល។
- បានចុះស្រង់ទិន្នន័យ៖
  - នៅឃុំឫស្សីក្រាំងគ្រួសារសរុប ៤,២៨១ គ្រួសារ, ខ្នងផ្ទះសរុប ២,៨១៥ ខ្នងលើ ១១ ភូមិ មានធុងចម្រោះចំនួន ២៤០ ធុង ស្រះសហគមន៍ ២៣ ស្រះ, ប្រព័ន្ធចែកចាយទឹកសហគមន៍ចំនួន ០១។
  - នៅឃុំព្រៃស្វាយ គ្រួសារសរុប ៣,៧២១ គ្រួសារ, ខ្នងផ្ទះសរុប ២,៨០២ ខ្នងលើ ៩ ភូមិ មានអណ្តូងស្នប់ចំនួន ១០ អណ្តូង, អណ្តូងខួចចំនួន ១០ អណ្តូង , អណ្តូងលូចំនួន ២ អណ្តូង, ធុងចម្រោះចំនួន ២៧២ ធុង, ស្រះសហគមន៍ចំនួន ២៥ ស្រះ, អាងត្រងទឹកភ្លៀងចំនួន ៣ អាង។

- នៅឃុំគារ គ្រួសារសរុប ៤,៥២៣ គ្រួសារ,ខ្នងផ្ទះសរុប ៣,២៦៧ ខ្នង លើ ១២ ភូមិ មានអណ្តូងស្នប់ចំនួន ០៤ អណ្តូង(ខូចទាំង ០៤),អណ្តូងលូចំនួន ១០ អណ្តូង, ធុងចម្រោះមាន ១០០ ធុង,ស្រះសហគមន៍ចំនួន ២៣ ស្រះ, ប្រពន្ធ័ចែកចាយទឹកសហគមន៍ចំនួន ១ ។

- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីសកម្មភាពការងារផ្គត់ផ្គង់ទឹកស្អាត ការលើកកម្ពស់អនាម័យជនបទ និងទឹកស្អាតជាមួយអង្គការដៃគូអភិវឌ្ឍន៍ប្រចាំត្រីមាសទី ១ ឆ្នាំ ២០២២ តាមរយៈប្រព័ន្ធ Microsoft Team ដែលមានអង្គការចូលរួមចំនួន ១១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធ Zoom ។
- បានសាងសង់អណ្តូងស្នប់ចំនួន ១៦ អណ្តូង នៅស្រុកថ្មគោល បាណន់ សង្កែ និងក្រុងបាត់ដំបង ។

### ៣.១.២. គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្គត់ផ្គង់សេវាកម្មទឹកស្អាត និងអនាម័យជនបទទី ៣

- បានសាងសង់អណ្តូងស្នប់ចំនួន ៧៥ អណ្តូង នៅឃុំស៊ុង ឃុំអូរសំរិល ស្រុកសំឡូត
- បានដឹកពាងចែកតាមខ្នងផ្ទះចំនួន ៧,៦៤៤ ពាង នៅឃុំស៊ុង ឃុំកំពង់ល្ពៅ ឃុំអូរសំរិល និងឃុំតាតោក ស្រុកសំឡូត។

## ៣.២. ការងារថែទាំសុខភាពអនាម័យ

### ៣.២.១. ការងារនៅក្នុងមន្ទីរ

- ចុះលើកផ្លាកភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ៣ ភូមិ(ODF)នៅឃុំអំពិលប្រាំដើម និងឃុំឃ្លាំងមាស ស្រុកបវេល ដោយមានអ្នកចូលរួមសរុបចំនួន នាក់ ក្នុងនោះស្ត្រី ៥ នាក់។
- ចុះផ្សព្វផ្សាយ និងអប់រំសហគមន៍ ពីលក្ខខណ្ឌនៃការរស់នៅស្អាត ដល់គ្រួសារតាមខ្នងផ្ទះបាន ៣០ ផ្ទះនៅ ឃុំឃ្លាំងមាស ស្រុកបវេល និងឃុំកកោះ ស្រុកមោងឫស្សី។
- បានចុះស្រង់ទិន្នន័យបង្គន់អនាម័យៈ
  - នៅឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ចំនួន ២១ ភូមិ និង ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ៨ ភូមិ និងចំនួន ៣ ភូមិទៀតដូចជាភូមិទួលព្រំ ១ អត្រាអនាម័យ ៧៨%, ភូមិចកតូច ៧១%, ភូមិរំចេក ៧៧% ។
  - នៅឃុំអូរដា ចំនួន ២ ភូមិ គឺភូមិថ្មី មានអត្រាអនាម័យ ៨៤% និងភូមិលំផាត់ ៨៦% មានអ្នកចូលរួមសរុប ៣២ នាក់ ស្រ្តី ២៣ នាក់
- ចូលរួមកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការអប់រំភាពជាអ្នកដឹកនាំ លើកម្មវិធីទឹកស្អាត និងអនាម័យជនបទ នៅសាលាខេត្តបាត់ដំបង ដោយមានអ្នកចូលរួមសរុប ៥៣ នាក់ ស្ត្រី ២៤ នាក់។
- បានធ្វើបច្ចុប្បន្នភាពភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល លទ្ធផលសម្រេចបានភូមិODF ចំនួន ១៥៨ ភូមិ លើ ៩ ឃុំ ជាឃុំODF រួមមានឃុំបាយដំរាំ,ជ្រៃ, ជ្រោយស្ដៅ, អូររំដួល,អូរតាគី ,កំពង់ព្រៀង,កំពង់ព្រះ,តាម៉ឺននិងឃុំព្រៃតូចដែលមានអត្រាអនាម័យក្នុងខេត្តចំនួន **៧៩%** ។

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារទឹកស្អាត និងអនាម័យសម្រាប់តំបន់ធម្មតា និងតំបន់ប្រឈម ស្តីពីគម្រូវប្លង់ និងការសាងសង់បង្គន់អនាម័យប្រកបដោយបរិយាបន្ន មានអ្នកចូលរួមសរុប ២៧ នាក់ ស្ត្រី ០៥ នាក់។

**៣.២.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទនិងការគាំទ្រកសិករ**

**ការងារសាងសង់បង្គន់អនាម័យសាធារណៈចំនួនសរុប ១២ កន្លែង**

- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅបឋមសិក្សាកាប់ព្រិច ភូមិកាប់ព្រិច ឃុំព្រះផុស ស្រុកគាស់ក្រឡ សម្រេចបាន ១០០% ។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅបឋមសិក្សាមិត្តភាព ភូមិសាមគ្គី ឃុំហប់ស្រុកគាស់ក្រឡ សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅអនុវិទ្យាល័យកុកគ្រោង ភូមិស្វាយយ៉ ឃុំមុខរាហ៍ ស្រុករុក្ខគិរី សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅអនុវិទ្យាល័យស្តុកប្រវិក ភូមិស្តុកប្រវិក ឃុំស្តុកប្រវឹក ស្រុករុក្ខគិរី សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅអនុវិទ្យាល័យរូង ១ ភូមិរូង ១ ឃុំព្រៃឡាច ស្រុករុក្ខគិរី សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅមណ្ឌលសុខភាពព្រៃតូច ភូមិព្រៃតូច ឃុំព្រៃតូច ស្រុកមោងឫស្សី សម្រេចបាន ១០០%
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅអនុវិទ្យាល័យព្រៃតូច ភូមិព្រៃតូច ឃុំព្រៃតូច ស្រុកមោងឫស្សី សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅអនុវិទ្យាល័យកកោះ ភូមិកកោះ ឃុំកកោះ ស្រុកមោងឫស្សី សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅអនុវិទ្យាល័យតាប៉ុនភូមិតាប៉ុន ឃុំតាប៉ុន ស្រុកសង្កែ សម្រេចបាន ១០០%។
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែងនៅបឋមសិក្សាបសែត ភូមិបសែត ឃុំតាប៉ុន ស្រុកសង្កែ សម្រេចបាន ១០០%
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅបឋមសិក្សាប្រឡាយថ្មី ភូមិបឹងទឹម ឃុំតាប៉ុន ស្រុកសង្កែ សម្រេចបាន ១០០%
- បានសាងសង់បង្គន់អនាម័យសាធារណៈ ០១ កន្លែង នៅបឋមសិក្សាទួលព្រំ ១ ភូមិទួលព្រំ ១ ឃុំកកោះ ស្រុកមោងឫស្សី សម្រេចបា ន១០០%។

(**បញ្ជាក់**:ក្នុងមួយកន្លែងៗមានបន្ទប់បង្គន់បុរសចំនួន ០៤ បន្ទប់ បង្គន់សម្រាប់ស្ត្រីចំនួន ០៤ បង្គន់នោមបុរសចំនួន ០៦ និងឡាបូលាងដៃចំនួន ០២។)

**៣.៣. ការងារអភិវឌ្ឍន៍សហគមន៍**

- ចុះទំនាក់ទំនង និងពិនិត្យទីតាំងសម្រាប់បណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិ

ការអភិវឌ្ឍន៍ភូមិ។

- ចុះសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីរៀបចំ គ.អ.ភ ភូមិទើបទទួលស្គាល់ថ្មីចំនួន ២១ ភូមិ។
- ចុះសហការ ជាមួយរដ្ឋបាលឃុំបវេល ដើម្បីរៀបចំបង្កើតគណកម្មាធិការអភិវឌ្ឍន៍ភូមិសំរោងជ័យ និងភូមិព្រៃតាឡូញ។
- ចុះសហការ ជាមួយរដ្ឋបាលឃុំកំពង់ល្ពៅ ដើម្បីជ្រើសបេក្ខភាព និងបំពេញបន្ថែមសមាស ភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ទាំង ០៩ ភូមិ ក្នុងឃុំកំពង់ល្ពៅ ស្រុកសំឡូត។
- ចូលរួមកិច្ចប្រជុំធ្វើបទបង្ហាញសាកល្បង របស់សមាជិកចលនាភូមិមួយផលិតផលមួយនៅសាលាខេត្ត។
- ចូលរួមទទួលការបំពាក់បំប៉នដោយផ្ទាល់លើការអនុវត្តការងារចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ នៅតាមសហគមន៍ក្នុងក្រុងបាត់ដំបង និងស្រុកសង្កែ ខេត្តបាត់ដំបង។
- គម្រោងកសាងសន្តិភាព និងភាពរុងរឿង៖
  - ចុះសិក្សាស្រាវជ្រាវមូលដ្ឋាននៅឃុំកំពង់ល្ពៅ និងឃុំតាតោក ស្រុកសំឡូត។
  - ប្រជុំ និងពិភាក្សាថ្នាក់ខេត្ត ជាមួយមន្ទីរពាក់ព័ន្ធលើស្ថានភាពអភិវឌ្ឍន៍ជនបទ សកម្មភាពកសិកម្ម និងតំរូវការសហគមន៍
  - ប្រមូលទិន្នន័យពីមន្ទីរពាក់ព័ន្ធដើម្បីរៀបចំគម្រោង

## ៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

### ៤.១. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- ចុះប្រមូលការប្រាក់ឥណទានក្រុម និងទោលបានចំនួន ៥,២២០,៦០០ រៀល។
- ចុះប្រមូលប្រាក់ដើម ឥណទានក្រុម និងទោលចំនួន ៣១,៩៤៧,៩០០ រៀល។
- សាច់ប្រាក់នៅលើដៃអតិថិជនក្រុម និងទោលចំនួន ៥៦,៣៥១,៣០០ រៀល មានអ្នកខ្ចីទោល ចំនួន ៨ នាក់ អ្នកខ្ចីក្រុមចំនួន ១០ ក្រុមស្មើនឹង ៤០ នាក់ ក្នុងនោះមានស្ត្រីចំនួន ២៦ នាក់ ក្នុងភូមិចំនួន ៣ ភូមិ ២ ឃុំ ២ ស្រុក-ក្រុង។

### ៤.២. ការងារអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច

ប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិច ពិភពលោកលើកទី ២៨ និងលើកទី១៨ នៅកម្ពុជា ក្រោមប្រធានបទ តួនាទីស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស និងការផ្ទេរចំណេះដឹងប្រពៃណី នៅឃុំតាតោក ស្រុកសំឡូត ដែលមានអ្នកចូលរួមសរុប ២២៦ នាក់ ស្ត្រី ១១៣ នាក់។

## ៥. សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ

### ការងារសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងអង្គការដៃគូរជាតិ

- អង្គការសរុបចំនួន ០៩ កំពុងអនុវត្តសកម្មភាព មានដូចជា អង្គការទស្សនៈពិភពលោក, Good Neighbor,Help Age Cambodia, ជីវិតថ្លៃថ្នូរ( LWD), ទឹកស្អាត

១០០១, Maddox Jolie Pit, Samaritan'sPurse, លំនៅដ្ឋានសម្រាប់មនុស្សជាតិកម្ពុជា ( Habitat for Humanity for Cambodia ), Action for Health Development(AHEAD)។

- ប្រជុំបូកសរុបលទ្ធផលការងារទឹកស្អាត និងអនាម័យជនបទ ប្រចាំឆមាសទី ១ ជាមួយអង្គការដៃគូសរុបចំនួន ៨ អង្គការ ដែលមានសកម្មភាពនៅក្នុងខេត្តមានអ្នកចូលរួមសរុប ១៦ នាក់ ស្ត្រី ០២ នាក់។
- ប្រជុំបូកសរុបលទ្ធផលការងារទឹកស្អាត និងអនាម័យជនបទ ត្រីមាសទី ១ ជាមួយអង្គការដៃគូរ ៩ តាមប្រព័ន្ធ online មានអ្នកចូលរួមចំនួន ១៥ នាក់ ស្ត្រី ៤ នាក់។
- ចូលរួមប្រជុំផ្សព្វផ្សាយគម្រោងផ្លាស់ប្តូរឥរិយាបថទឹកស្អាត និងអនាម័យ លើស្រុកភ្នំព្រឹក ស្រុកសំពៅលូននិងស្រុកកំរៀងរបស់អង្គការ AHEAD ដោយមានអ្នកចូលរួមចំនួន ២៣ នាក់ ស្ត្រី ៨ នាក់។
- ចូលរួមប្រជុំផ្សព្វផ្សាយការត្រៀមអនុវត្តគម្រោង ទឹកស្អាត និងអនាម័យ របស់អង្គការសាម៉ារីតាន់ផឺស នៅសាលាស្រុកកំរៀង ដោយមានអ្នកចូលរួមសរុបចំនួន ៣៥ នាក់ស្ត្រី ១០ នាក់។
- ចូលរួមប្រជុំផ្សព្វផ្សាយការត្រៀមអនុវត្តគម្រោងទឹកស្អាត និងអនាម័យរបស់អង្គការសកម្មភាពដើម្បីការអភិវឌ្ឍន៍ និងនាយកដ្ឋានថែទាំសុខភាពជនបទ សម្រាប់ខេត្តបាត់ដំបង និងខេត្តកំពង់ឆ្នាំង ដោយមានអ្នកចូលរួមសរុបចំនួន ២៦ នាក់ ស្ត្រី ១០ នាក់។
- ចុះផ្ទៀងផ្ទាត់ភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ជាមួយអង្គការទស្សនៈពិភពលោក( WVC )បានចំនួន ០៥ ភូមិ នៅភូមិអណ្តូងកន្លែង ភូមិប្រឡាយ ១៨ ភូមិបឹងត្របែក នៃឃុំស្តុកប្រវឹកនិងភូមិមុខរាហ៍, ភូមិមុខរាហ៍ ២ ឃុំមុខរាហ៍ ស្រុករុក្ខគិរីដោយមានអ្នកចូលរួមសរុប ៣៩៦ នាក់ ស្ត្រី ២០៥ នាក់ក្នុងនោះអ្នកមានបង្គន់ចំនួន ៣៦៥ នាក់ និងប្រើរួម ៣០ នាក់។

## II. បញ្ហាប្រឈម

- ខ្សែផ្លូវមានច្រើនជាងគេក្នុងខេត្តបាត់ដំបង ប៉ុន្តែថវិកាសម្រាប់គាំទ្រគម្រោង ថែទាំផ្លូវពុំអាចឆ្លើយតបបាន។
- ទម្លាក់ថវិកាមិនទាន់ពេលវេលា។
- គ្មានកន្លែងស្នាក់នៅសម្រាប់សិស្សមកពីឆ្ងាយ។
- ថវិកាជាតិមានកំរិតសម្រាប់ការឆ្លើយតបការងារសាងសង់សំណង់ផ្គត់ផ្គង់ទឹកជនបទ។
- សហគមន៍ខ្វះការយកចិត្តទុកដាក់ថែរក្សាសំណង់ផ្គត់ផ្គង់ទឹកជនបទ។
- យុទ្ធនាការណ៍អប់រំក្នុងមូលដ្ឋានពុំទាន់ដំណើរការល្អ ធ្វើតែតំបន់មានអង្គការដៃគូ។
- ក្រសួងមិនបានទម្លាក់ថវិកាសម្រាប់ការសាងសង់បង្គន់ជូនប្រជាពលរដ្ឋ។
- ការទម្លាក់ថវិកាថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលមានភាពយឺតយ៉ាវ។
- វគ្គបណ្តុះបណ្តាលផ្តល់ជូនមន្ត្រីរាជការនៅមានកំរិត។

- ស្ថានប័នមីក្រូហិរញ្ញវត្ថុច្រើន អតិថិជនចំណាកស្រុក ទីផ្សារកសិផលចុះថោក និងអតិថិជនមួយចំនួនតូចគ្មានទំនួលខុសត្រូវ នាំឲ្យការសងប្រាក់មានការយឺតយ៉ាវ។

## III. ទិសដៅការងារឆ្នាំ២០២៣

### ១. ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

#### ១.១ ការងាររដ្ឋបាល និងបុគ្គលិក

បន្តជំរុញការងារគ្រប់គ្រងលិខិតបទដ្ឋាន និងការងារដំឡើងកាំប្រាក់ និងមុខងារជូនបុគ្គលិកមន្ត្រីរាជការដែលមានស្នាដៃ ព្រមទាំងតាមដានបញ្ជីវត្តមានជាប្រចាំ ។

#### ១.២. ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយដល់មន្ត្រីរាជការ

- បន្តបណ្តុះបណ្តាលជំនាញកាត់ដេរសម្លៀកបំពាក់ចំនួន ០៦ វគ្គ អ្នកទទួលផល ១២០ នាក់។
- បន្តបណ្តុះបណ្តាលជំនាញកាត់សក់បុរសចំនួន ០៦ វគ្គ អ្នកទទួលផល ១២០ នាក់។
- បន្តបណ្តុះបណ្តាលជំនាញជួសជុលម៉ាស៊ីនកសិកម្ម ចំនួន ០៦ វគ្គ អ្នកទទួលផល ១២០ នាក់។
- បន្តបណ្តុះបណ្តាលជំនាញបណ្តុះផ្សិតចំបើង ចំនួន ០៩ វគ្គ អ្នកទទួលផល ១៨០ នាក់។
- បន្តបណ្តុះបណ្តាលជំនាញចិញ្ចឹមចង្រិត ចំនួន ០៩ វគ្គ អ្នកទទួលផល ១៨០ នាក់។
- បន្តរៀបចំផែនការសម្រាប់បណ្តុះបណ្តាល ដល់មន្ត្រីរាជការបន្ថែមទៀត។

#### ១.៣. ការងារផែនការ និងស្ថិតិ

បន្តត្រួតពិនិត្យសកម្មភាពនានាតាមផែនការដែលបានលើកឡើងដើម្បីកែតម្រូវនិងធ្វើបច្ចុប្បន្នភាពផែនការប្រចាំឆ្នាំ ឲ្យកាន់តែមានភាពសុក្រឹត ត្រៀមកែតម្រូវរាល់គ្រប់ឯកសារចំណូលចំណាយតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាឆ្នាំកន្លងមក។

### ២. ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍

#### វិស័យផ្លូវជនបទ

ខិតខំអនុវត្តផែនការ ដែលបានអនុម័តពីក្រសួងអភិវឌ្ឍន៍ជនបទ និងការចង្អុលណែនាំផ្ទាល់ពីឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី,ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តមអភិបាលខេត្តដូចជាៈ

- ត្រៀមជួសជុល ថែទាំផ្លូវក្រាលក្រួសក្រហម និងក្រាលល្បាយកំទេចថ្មភ្នំ សរុបចំនួន ៤៥ ខ្សែ ប្រវែង ៥៩៩.៣០ គ.ម ក្នុងស្រុកបាណន់ ស្រុកសំពៅលូន កំរៀង ភ្នំព្រឹក សំឡូត បវេល ថ្មគោល រតនមណ្ឌល គាស់ក្រឡ មោងឫស្សី និងស្រុកសង្កែ។
- ត្រៀមជួសជុល ថែទាំផ្លូវក្រាលកៅស៊ូស្តាឡើងវិញ សរុបចំនួន ១១ ខ្សែ ប្រវែង ១២៩.៤៥គ.ម ក្នុងស្រុកសំពៅលូន រតនមណ្ឌល រុក្ខគិរី មោងឫស្សី គាស់ក្រឡ សង្កែ បាណន់ និងក្រុងបាត់ដំបង។
- ត្រៀមជួសជុល ថែទាំផ្លូវក្រាលកៅស៊ូ ២ ស្រទាប់ សរុបចំនួន ១៦ ខ្សែ ប្រវែង ១៩៦.៥០ គ.ម ក្នុងស្រុកថ្មគោល ឯកភ្នំ បាណន់ មោងឫស្សី សង្កែ រុក្ខគិរី រតនមណ្ឌល និងក្រុងបាត់ដំបង។
- បន្តធ្វើបច្ចុប្បន្នភាព និងចុះត្រួតពិនិត្យគម្រោងជួសជុលផ្លូវថែទាំជាប្រចាំ ។
- បន្តដាំកូនឈើអមសងខាងផ្លូវជនបទ។

- បន្តរាប់យានយន្តចរាចរលើផ្លូវជនបទ។

**៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**៣.១. វិស័យទឹកស្អាត**

- ត្រៀមសាងសង់អណ្ដូងស្នប់ ចំនួន ៤៤ អណ្ដូង លើ ៧ ស្រុក។
- ត្រៀមស្រង់ទិន្នន័យអណ្ដូង ចំនួន ២ ០០០ អណ្ដូង លើ ៥ ស្រុក។

**៣.២. វិស័យអភិវឌ្ឍសហគមន៍**

- បន្តបណ្ដុះបណ្ដាល គ.អ.ភ ស្ដីពីផែនការសកម្មភាពភូមិ ចំនួន ៣០ វគ្គ អ្នកទទួលផល ១០៥០ នាក់។
- បន្តចុះបច្ចុប្បន្នភាពនិងពិនិត្យគ.អ.ភ ចំនួន ១៥០ ភូមិ អ្នកទទួលផល ១ ៣៥០ នាក់។

**៣.៣. វិស័យសុខភាពជនបទ**

- ត្រៀមស្រង់ទិន្នន័យសារពើភ័ណ្ឌបង្គន់អនាម័យ ១០២ ឃុំ។
- ត្រៀមផ្ដល់សម្ភារៈបង្គន់អនាម័យ ដល់ប្រជាពលរដ្ឋចំនួន ២ ១៦២ គ្រួសារ លើ ៥ស្រុក។

**៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- បន្តផ្ដល់គំនិតបង្កើតអាជីវកម្មខ្នាតគ្រួសារ និងសហគ្រិនភាព លើ ៣០ ភូមិ។
- បង្កើតក្រុមសន្សំប្រាក់សហគមន៍ លើ ២៨ ភូមិ អ្នកទទួលផល ៥ ៦០០ នាក់។
- បន្តធ្វើបច្ចុប្បន្នភាពជនជាតិដើមភាគតិចព័រ និងផ្សព្វផ្សាយលក្ខន្តិកៈចំនួន ១៧១ គ្រួសារ។

**៥. សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

- បន្តសហការ និងស្វែងរកដៃគូអភិវឌ្ឍន៍ផ្សេងៗ។
- បង្កើតទំនាក់ទំនងអោយកាន់តែប្រសើរឡើងជាមួយ ស្ថាប័ន អង្គការ ដែលពាក់ព័ន្ធ។

## IV. សេចក្ដីសន្និដ្ឋាន

ការងារគ្រប់ផ្នែកនៃមន្ទីរអភិវឌ្ឍន៍ជនបទ ដែលបានអនុវត្តជាក់ស្ដែងក្នុងឆ្នាំ ២០២២ ត្រូវបានបញ្ចប់ ១០០% លទ្ធផលទាំងនេះគឺពិតជាបានមកពីការខិតខំយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ពិសេស **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ព្រមទាំងនាយកដ្ឋាននានាដែលបានជួយបង្កភាពងាយស្រួលទាំងស្មារតី សម្ភារថវិកាជាប្រភពទុនដ៏សំខាន់ជាការលើកទឹកចិត្ត ក៏ជាចលករជំរុញឲ្យមន្ទីរបំពេញភារកិច្ចអភិវឌ្ឍន៍តាមមូលដ្ឋានបានយ៉ាងល្អប្រសើរ ក្នុងការលើកកម្ពស់តួនាទី និងឥទ្ធិពលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានវាយតម្លៃខ្ពស់លើការគាំទ្រពីអាជ្ញាធរខេត្ត និងស្ថាប័នជំនាញនានាក្នុងខេត្ត។

ទន្ទឹមនឹងនេះដោយទទួលបាននូវការចង្អុលណែនាំឯកឧត្តមក្រុមប្រឹក្សាខេត្ត ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ប្រជាពលរដ្ឋទូទាំងខេត្ត ដៃគូអភិវឌ្ឍន៍នានា និងការខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចតាមតួនាទីរបស់មន្ត្រីរាជការម្នាក់ៗក្នុងអង្គភាពមន្ទីរ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងអាណត្តិទី ៦ នេះ បានធ្វើឲ្យមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចូលរួមចំណែកយ៉ាងសកម្មក្នុងការជំរុញ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរួមចំណែកកាត់

បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋទូទាំងប្រទេសស្របតាមគោលដៅជាយុទ្ធសាស្ត្រ ដែលក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់។